# លំផាត់

**A1, A2, A3 & A4i**



| | | |
|---|---|---|
| **ខេត្ត** | : | ស្ទឹងត្រែង ក្រចេះ រតនគិរី និង មណ្ឌលគិរី |
| **ស្រុក** | : | សេសាន សម្បូរ កូនមុំ លំផាត់ និង កោះញែក |
| **ផ្ទៃដី (ហិកតា)** | : | ៣០៦.៣៩៧ |
| **រយៈកំពស់ (ម៉ែត្រ)** | : | ៩០ ដល់ ១៦០ |
| **កូអរដោនេចំណុចកណ្តាល** | : | ១៣$^{0}$២៣´ ជ ១០៦$^{0}$ ៣៨´ ក |

### ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានតំបន់ព្រៃរបោះដែលលាតសន្ធឹងពីផ្នែកខាងលិចនៃតំបន់ទីជំរកសត្វព្រៃលំផាត់រហូតដល់ប៉ែកខាងជើង និង ខាងលិចនៃកន្លែងប្រសព្វរវាងទន្លេសេសាន និង ទន្លេស្រែពក ។ ទន្លេស្រែពក និង រុក្ខជាតិដែលក្នុងប្រព័ន្ធរបស់វាគឺត្រូវរួមបញ្ចូលទៅក្នុងតំបន់ IBA នេះ និង មាត់ទន្លេទាំងសងខាងក៏ត្រូវរួមបញ្ចូលផងដែរ ។ ផ្នែករបស់ទន្លេស្រែពករួមបញ្ចូលក្នុងតំបន់ IBA នេះ មានទទឹងប្រហែល២០០ម៉ែត្រ ដោយបាតទន្លេសម្បូរទៅដោយថ្ម និង ព្រៃគុម្ពោត ។ រុក្ខជាតិដែលដុះនៅក្នុងតំបន់នេះគ្របដណ្តប់ដោយព្រៃរបោះ តែពុំមានគ្រប់ទីកន្លែងនោះទេ និង ព្រៃពាក់កណ្តាលស្រោង ។ ព្រែក និង អូរដែលមានទឹកតាមរដូវកាល ជានិច្ចកាលអមទៅដោយព្រៃឈើធំល្វឹងល្វើយ និង មានត្រពាំងជាច្រើន ដែលភាគច្រើនមានទឹកតាមរដូវកាល ។ ត្រពាំងទាំងនេះមានវិជ្ជមាត្រតូចជាង១០០ម៉ែត្រ ប៉ុន្តែជានិច្ចកាលមានដុះស្មៅលិចទឹកតាមរដូវកាលផងដែរ ដែលមានប្រវែងរហូតដល់រាប់រយម៉ែត្រ ។

តំបន់នេះបានទ្រទ្រង់ពពួកសត្វស្លាបដែលរស់នៅក្នុងតំបន់ព្រៃរបោះចំកណ្តាលតំបន់ឥណ្ឌូចិន ។ វាលស្មៅលិចទឹកតាមរដូវកាល គឺជាតំបន់ពងកូនយ៉ាងសំខាន់សម្រាប់សត្វក្រៀល រីឯត្រពាំងទាំងឡាយមានសារៈសំខាន់សម្រាប់សត្វស្លាបទឹកធំៗមួយចំនួនរួមមានត្រយ៉ងយក្ស និង ត្រដក់តូច ។ តំបន់ IBA នេះ រួមបញ្ចូលទាំងត្រពាំងរកា ជាតំបន់សើមដែលស្ថិតនៅចន្លោះរវាងទន្លេស្រែពក និង ទន្លេសេសាន ដែលត្រយ៉ងចំកំកសត្រូវបានសង្កេតឃើញនៅឆ្នាំ ១៩៩៨ ។ ទន្លេស្រែពកបានទ្រទ្រង់នូវប្រភេទសត្វរស់តាមដងទន្លេមួយចំនួន ដូចជាពពូលទឹក និង ខ្ញប់ដីមេគង្គលើ ។ ភាពសម្បូរនៃពពួកសត្វធំៗមានក្រចកជំពាមមានន័យថាតំបន់នេះមានសក្តានុពលខ្ពស់ក្នុងការទ្រទ្រង់ចំនួនរបស់ត្មាតផេះ ត្មាតត្នោត និង ត្មាតភ្លើងច្រើនជាងបណ្តាតំបន់ផ្សេងៗទៀតនៅក្នុងតំបន់អាស៊ីអគ្នេយ៍ ។

### ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| ក្ងោក | Green Peafowl | *Pavo muticus* | A1 | |
| ក្រៀល | Sarus Crane | *Grus antigone* | A1 | |
| ខ្ញប់ដីមេគង្គលើ | Mekong Wagtail | *Motacilla samveasnae* | A1 | A2 |
| ចាបពូកទ្រូងលឿង | Asian Golden Weaver | *Ploceus hypoxanthus* | A1 | |
| ត្មាតត្នោត | Long-billed Vulture | *Gyps indicus* | A1 | |
| ត្មាតផេះ | White-rumped Vulture | *Gyps bengalensis* | A1 | |

| | | | | |
|---|---|---|---|---|
| ត្មាតភ្លើង | Red-headed Vulture | *Sarcogyps calvus* | A1 | |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 | |
| ត្រដក់ធំ | Greater Adjutant | *Leptoptilos dubius* | A1 | |
| ត្រយ៉ងចំកំក ស | White-shouldered Ibis | *Pseudibis davisoni* | A1 | |
| ត្រយ៉ងយក្ស | Giant Ibis | *Pseudibis gigantea* | A1 | A4i |
| ពពូលទឹក | Masked Finfoot | *Heliopais personata* | A1 | |
| ស្ទាំងស្លាបស្រួចចុងខ្នងស | White-rumped Falcon | *Polihierax insignis* | A1 | |
| អង្កត់ខ្មៅ | Black-necked Stork | *Ephippiorhynchus asiaticus* | A1 | |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង និង ប្រាំបីប្រភេទរស់ក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

រញ៉ៃភ្លើង ស្វាត្រោស ស្វាកាម ស្វាអង្កត់ ស្វាព្រាម និង ស្វាក្រវ៉ាត ។

**ដីរី និង ពពួកក្រចកជំពាចទទួលរងការគំរាមកំហែងពិភពលោក**

ដំរី រមាំង ខ្ទីង និង ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

ក្រពើទន្លេ (ក្រពើត្រី) កន្ធាយអាស៊ី អណ្តើងសោមញី អណ្តើកក្របីក្បាលលឿង អណ្តើកព្រិច និង កន្ធាយក្បាលកង្កែប ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការគំរាមកំហែងចំបង គឺការបរបាញ់ក្រុមថនិកសត្វ និង សត្វស្លាបមាឌធំៗដូចជា ក្រៀល និង ក្ងោក ។ នៅជុំវិញបណ្តាតំបន់នៅខាងក្រៅតំបន់ IBA ការថយចុះ និង ការបាត់បង់ទីជំរកដោយការធ្វើអាជីវកម្មឈើហ៊ុប និង ការប្រែក្លាយតំបន់វាលស្មៅលិចទឹកតាមរដូវកាលទៅជាដី កសិកម្មគឺជាការព្រួយបារម្ភមួយ ។ ប៉ុន្តែ សកម្មភាពទាំងនេះគឺមានលក្ខណៈកំណត់ក្នុងតំបន់ IBA ។ នៅតាមដងទន្លេស្រែពក ការកាប់ព្រៃឈើ និង ការរានដីព្រៃសម្រាប់ធ្វើកសិកម្មនាំឱ្យមានការថយចុះ និង បាត់បង់ព្រៃឈើដុះតាមប្រព័ន្ធទន្លេ រីឯរបៀបនៃការនេសាទបំផ្លិចបំផ្លាញ ជាពិសេស ការប្រើប្រាស់ថ្នាំពុល និង គ្រឿងផ្ទុះ គឺជាការព្រួយបារម្ភផងដែរ ។ ទោះជាយ៉ាងណាក្តី ការគំរាមកំហែងចំបងៗលើប្រភេទសត្វស្លាបរស់តាមដងទន្លេ ទំនងជាការបរបាញ់ ការប្រមូលយកពងកូន និង ការរំខានដោយសារសកម្មភាពមនុស្សនៅវាលខ្សាច់ ។ ការគំរាមកំហែងខ្លាំងក្លានាពេលអនាគត គឺជាការអភិវឌ្ឍន៍គំរោងវារីអគ្គិនីនៅក្នុងទន្លេស្រែពក ។

**អនុសាសន៍**

វិធានការដើម្បីបង្រ្កាបការបរបាញ់ និង ការធ្វើពាណិជ្ជកម្មសត្វព្រៃត្រូវអនុវត្តនៅក្នុងតំបន់គ្រប់ទីកន្លែង ។ សកម្មភាពនេះគួរចាប់ផ្តើមបង្កើតឡើងនូវប្រព័ន្ធល្បាតក្នុងដែនជំរកសត្វព្រៃលំផាត់ និង ក្នុងតំបន់ព្រៃអភិរក្សខេត្តមណ្ឌលគីរី ។

ការអភិរក្សផ្នែកសំខាន់ៗនៃទន្លេស្រែពកគួរតែរួមបញ្ចូលទាំងអស់នៃការគ្រប់គ្រងតំបន់អភិរក្សដែលមានស្រាប់ ។ ទោះជាយ៉ាងណាក៏ដោយ វិធានការអភិរក្សត្រូវអនុវត្តតាមបណ្តោយប្រព័ន្ធទន្លេទាំងអស់ ដោយរួមបញ្ចូលទាំងតំបន់ផ្ទៃរងទឹកភ្លៀង

ទន្លេស្រែពកខាងលើ IBA（KH0025） ពីព្រោះការផ្តោតលើផ្នែកតូចៗដែលដាច់ៗពីគ្នារបស់ទន្លេនាំអោយមានផលវិបាក និងភាពមហន្តរាយ ។

ការប្រឹងប្រែងត្រូវតែធ្វើឡើងដើម្បីការពារប្រភេទសត្វស្លាបដែលពងកូនលើវាលខ្សាច់ ខណៈដែលពួកវាកំពុងពងកូន ។ កិច្ចព្រមព្រៀងសហគមន៍អាចបង្កើតឡើងតាមភូមិនិមួយៗ ដើម្បីកុំឱ្យតំបន់ទាំងនោះមានការរំខាន ។

ការតាំងទីលំនៅខុសច្បាប់ និង ការទន្ទ្រានយកដីចូលទៅក្នុងតំបន់សំខាន់ៗរបស់ IBA គួរត្រូវហាមឃាត់ ។

ការបង្កើតភូមិថ្មីៗ និង ការអភិវឌ្ឍន៍កសិកម្មតាមដងទន្លេស្រែពកមិនគួរត្រូវបានលើកទឹកចិត្តឡើយ ហើយផ្នែកសំខាន់ៗដែលមានព្រៃឈើដុះតាមប្រព័ន្ធទន្លេ គួរតែការពារឱ្យបានតឹងរឹងពីការកាប់រំលំ និង ការធ្វើកសិកម្មពនេចរ ។

ការដៅលើផែនទីនូវទីតាំងតំបន់ដីសើមសំខាន់ៗ តំបន់ពងកូនរបស់ប្រភេទសត្វសំខាន់ៗ និង តំបន់មានវត្តមានមនុស្សនៅក្នុងតំបន់ IBA គួរតែត្រូវធ្វើឡើង ។ បញ្ហានេះនឹងតម្រូវឱ្យមានការសិក្សាស្រាវជ្រាវបន្ថែម ជាពិសេស នៅតាមតំបន់ស្ថិតនៅខាងត្បូងទន្លេស្រែពក ដែលគេបានដឹងបន្តិចបន្តួចនៅឡើយអំពីសត្វព្រៃ និង គួរតែត្រូវប្រើប្រាស់ដើម្បីបង្កើតផែនការអភិរក្ស ។

ការទទួលស្គាល់ទំនាក់ទំនងនៃផែនការអភិវឌ្ឍន៍ខាងលើនៅថ្នាក់ជាតិ និង ថ្នាក់ខេត្ត ។

ការសិក្សាស្រាវជ្រាវបន្តនៅតាមបណ្តោយទន្លេស្រែពកចាំបាច់ត្រូវធ្វើឡើង ដោយផ្តោតលើការកំណត់ផ្នែកសំខាន់ៗនៃព្រៃឈើដែលដុះតាមប្រព័ន្ធទន្លេ និង ព្រៃក អូរតូចៗ ហើយកំណត់ឱ្យបានច្បាស់លាស់នូវចំនួន និង ដំណើរការជោគជ័យនៃការបង្កាត់ពូជរបស់ប្រភេទដែលពងកូនលើវាលខ្សាច់ ។

## ឯកសារយោង


Barzen, J. (2001) Waterbirds and wetlands of northern Cambodia. *Bugle* 27(4): 1-2.

Barzen, J. (2002) Waterbirds and wetlands of northern Cambodia. *Cambodia Bird News* 9:36-38.

Davidson, P., Poole, C. M. and Duckworth J. W. (2001) Mekong Wagtail (*Motacilla samvaesnae*): the great river's only known avian endemic. *Bull. Oriental Bird Club* 34: 56-59.

Desai, A. and Lic Vuthy (1996) *Status and distribution of large mammals in eastern Cambodia: results of the first foot surveys in Mondulkiri and Ratanakiri provinces*. Hanoi: IUCN/FFI/WWF.

Duckworth, J. W., Alström, P., Davidson, P., Evans, T. D., Poole, C. M., Tan Setha and Timmins, R. J. (2001) A new species of wagtail from the lower Mekong basin. *Bull. Brit. Ornith. Club* 121(3): 152-182.

Goes, F. ed. (1999) Recent sightings. *Cambodia Bird News* 1: 20-23.

Goes, F. (1999) Notes on selected bird species in Cambodia. *Forktail* 15: 25-27.

Net Neath *et al.* (2001) *A tiger survey of Lomphat Wildlife Sanctuary, Cambodia*. Phnom Penh: Department of Nature Conservation and Protection, Ministry of Environment.

Poole, C. M. Duckworth, J. W. and van Zalinge, N. J. (in prep.) Bird observations from the Mekong and major tributaries in north-east Cambodia, 1998-2000.

Tan Setha (2002) Mekong Wagtail: a species new to science discovered in northeast Cambodia. *Cambodia Bird News* : 9: 14-17.

Timmins, R. J. and Men Soriyun (1998) *A wildlife survey of the Tonle San and Tonle Srepok river basins in north-east ern Cambodia.* Hanoi and Phnom Penh: Fauna & Flora International and the Wildlife Protection Office.

van Zalinge, N. J., Poole, C. M., Duckworth, J. W. and Goes, F. (2002) Waterbird counts on the Mekong, Sekong, Sesan and Srepok rivers. *Cambodia Bird News* 9: 18-29.